# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការក្រសួងយុត្តិធម៌**
លេខ ៣៣០.កយ.រប-២០០៦

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>គោរពជូន</u>**

# ឯកឧត្តម ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
# ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**<u>កម្មវត្ថុ:</u>** ស្តីអំពីការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរ ពាក់ព័ន្ធនឹងការផ្ទេរអចលនវត្ថុ ។

**<u>យោង:</u>** ច្បាប់ស្តីអំពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩២

-ច្បាប់ស្តីអំពីប្រាក់ប្រដាប់ក្តីចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣

-សេចក្តីបង្គាប់លេខ ១១៧ សរ.រវ.៩៧ ចុះថ្ងៃទី៣១-០១-១៩៩៧ របស់ក្រសួងយុត្តិធម៌ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាជ្រាបថា កន្លងមកក្រសួងយុត្តិធម៌មិនបានពិនិត្យឃើញថា ក្រោយពីតុលាការបានសម្រេចលើរឿងក្តីរដ្ឋប្បវេណីចប់សព្វគ្រប់ទៅតាមនីតិវិធី និងច្បាប់រួចហើយ ភាគីឈ្នះក្តីមួយចំនួនបានយកសាលក្រម សាលដីកាស្ថាពរពីតុលាការទៅប្រគល់ជូនមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត/ក្រុង ដើម្បីស្នើសុំផ្ទេរសិទ្ធិតាមអំណាចសាលក្រម ឬសាលដីកាស្ថាពរដោយខ្លួនឯង។ ជាក់ស្តែងមានករណីខ្លះបានផ្ទេរហួតដល់ជនទីបីដែលក្រោយពីការផ្ទេរសិទ្ធិស្រប តាមនីតិវិធីសុរិយោដីរួចក៏មានបណ្តឹងតតីយជនប្តឹងជំទាស់សាលក្រមឬសាលដីកាស្ថាពរនោះ ។ ម្យ៉ាងទៀតក៏មានភាគីឈ្នះក្តីខ្លះបានយកសាលក្រម ឬសាលដីកាស្ថាពរនោះទៅអនុវត្តដោយពុំទាន់បានបង់ពន្ធសមាមាត្រ ដែលសាលក្រមឬសាលដីកាស្ថាពរនោះបានសម្រេចផងដែរ ។ ជាហេតុបង្កឱ្យមានការលំបាក និងស្មុគ្រស្មាញក្នុងការដោះស្រាយបញ្ហាទាំងនេះ និងខាតបង់ថវិកាជាតិ ។

ដោយផ្អែកតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៩២ ច្បាប់ស្តីអំពីប្រាក់ប្រដាប់ក្តី ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៣ និងសេចក្តីបង្គាប់លេខ១១៧ សរ.រវ.៩៧ ចុះថ្ងៃទី៣១-០១-១៩៨៧ របស់ក្រសួងយុត្តិធម៌ ស្តីពីការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ខ្ញុំសូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តា ជូនដំណឹងដល់គ្រប់អង្គភាពសុរិយោដី ដែលមានសមត្ថកិច្ចអនុវត្តភារៈកិច្ចតាមអំណាចសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការជ្រាបថា ក្នុងករណីមានភាគីឈ្នះក្តីបានយកសាលក្រមឬសាលដីកាស្ថាពរ ទៅស្នើសុំផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុនោះ អាជ្ញាធរសុរិយោដី មានសមត្ថកិច្ចត្រូវតម្រូវឱ្យភាគីឈ្នះក្តីយកភ្ជាប់មកជាមួយនូវកំណត់ហេតុអនុវត្តសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ ។ ក្នុងករណីភាគីឈ្នះក្តីពុំមានសំអាងណាមួយបញ្ជាក់ថា សាលក្រម ឬសាលដីកាស្ថាពរនោះ ត្រូវបានអនុវត្តដោយតុលាការទេ អាជ្ញាធរសុរិយោដីមិនអាចធ្វើការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុតាមសំណើរបស់ភាគីឈ្នះក្តីនោះបានឡើយ ហើយជួយណែនាំឱ្យភាគីឈ្នះក្តីនោះទៅស្នើសុំការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរនោះពីតុលាការសិន ។

ខ្ញុំសង្ឃឹម និងជឿជាក់ថា កាលបើអាជ្ញាធរសុរិយោដីអនុវត្តតាមការណែនាំខាងលើបានត្រឹមត្រូវ អំណើះតទៅនឹងកាត់បន្ថយបានរាល់បញ្ហាដែលកើតឡើងដូចបានជម្រាបជូនខាងលើជាក់ជាពុំខាន ។

សូម ឯកឧត្តមទេសរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**អង្គ វង្សវឌ្ឍនា**

<u>ចម្លងជូន</u>

-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-តុលាការខេត្ត/ ក្រុង
-ដើម្បីជូនជ្រាប
-ឯកសារ-កាលប្បវត្ត